**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៤៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់គ្រប់គ្រង និង អភិរក្សដែនបម្រុងសត្វក្រៀល និង សត្វស្លាបផ្សេងទៀត ស្ថិតនៅបឹងព្រែកល្ពៅ ស្រុកបុរីជលសារ និង ស្រុកកោះអណ្តែត ខេត្តតាកែវ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខា-ប្រមាញ់ទៅជារដ្ឋបាលព្រៃឈើ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៧

# ស ម្រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅបង្កើតតំបន់គ្រប់គ្រង និង អភិរក្សដែនបម្រុងសត្វក្រៀល និងសត្វស្លាបផ្សេងទៀត ស្ថិតនៅបឹងព្រែកល្ពៅ ស្រុកបូរីជលសា និងស្រុកកោះអណ្តែត ខេត្តតាកែវ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលបំណង ÷

- ការពារ អភិរក្សសត្វក្រៀល សត្វស្លាបផ្សេងទៀត មច្ឆជាតិ និង ធនធានសេនេទិចរុក្ខជាតិ ពិសេសប្រភេទជិតផុតពូជ និង ប្រភេទដែលកំពុងទទួលរងគ្រោះ ព្រមទាំងរក្សាលំនឹងមជ្ឈដ្ឋានធម្មជាតិ និង ទីជម្រករបស់វា

- ការពារ និង ថែរក្សាប្រភពទឹក ឱ្យមានប្រក្រតីភាពសម្រាប់ជីវៈចម្រុះ និង ការស្រោចស្រពក្នុងវិស័យកសិកម្ម ព្រមទាំងទ្រទ្រង់ឱ្យមានការអភិវឌ្ឍ ដែលធានាឱ្យមាននិរន្តរភាពតំបន់អេកូឡូស៊ី សេដ្ឋកិច្ចសង្គម និង ជីវភាពរស់នៅ

- ទ្រទ្រង់សកម្មភាពផ្សេងៗ រួមមានការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេស ការអប់រំ ផ្សព្វផ្សាយ បណ្តុះបណ្តាល អភិវឌ្ឍសហគមន៍ ការអង្កេតតាមដានពីភាពប្រែប្រួលបរិស្ថាន ដែលទាក់ទងនឹងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ការអភិរក្សនៅក្នុងកម្រិតមូលដ្ឋាន កម្រិតជាតិ និង កម្រិតតំបន់ ។

## ជំពូកទី ២
## ការកំណត់តំបន់

**មាត្រា ៣.-**

តំបន់គ្រប់គ្រង និង អភិរក្សដែនបម្រុងសត្វក្រៀល និង សត្វស្លាបផ្សេងទៀត មានផ្ទៃក្រឡាទំហំ **៨.៣០៥** ហិកតា (ប្រាំបីពាន់បីរយប្រាំហិកតា) ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធជាប្រព័ន្ធខ្សែព្រំបិទ កំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកា : **A** (498049, 1192141); **B** (497888, 1183698); **C** (497895, 1182741); **D** (504063, 1182737); **E** (508012, 1185033); **F** (508001, 1188152); **G** (507635, 1188401); **H** (507607, 1189159); **I** (507626, 1189899); **J** (507620, 1189975); **K** (506012, 1189966); **L** (505992, 1191709) ។

**មាត្រា ៤.-**

ផ្ទៃក្រឡាតំបន់គ្រប់គ្រង និង អភិរក្សដែនបម្រុងសត្វក្រៀល និង សត្វស្លាបផ្សេងទៀត ដែលកំណត់ក្នុងមាត្រា៣ អាចធ្វើការកែប្រែតាមការចាំបាច់ ដោយផ្អែកលើព័ត៌មានវិទ្យាសាស្ត្រជាមូលដ្ឋាន និង ស្ថានភាពជាក់ស្តែងនាពេលអនាគត ។ ការកែប្រែនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣
## ការចាត់ថ្នាក់ និង ការគ្រប់គ្រង

**មាត្រា ៥.-**

តំបន់គ្រប់គ្រង និង អភិរក្សដែនបម្រុងសត្វក្រៀល និង សត្វស្លាបផ្សេងទៀត ស្ថិតនៅបឹងព្រែកល្ពៅ ស្រុកបូរីជលសា និង ស្រុកកោះអណ្តែត ខេត្តតាកែវ ត្រូវបានបែងចែកជាពីរតំបន់គឺ តំបន់ស្នូល និង តំបន់ទ្រនាប់ ដែលមានព្រំប្រទល់ដូចខាងក្រោម ÷

១-តំបន់ស្នូល មានទីតាំងស្ថិតនៅក្នុងឃុំកំពង់ក្រសាំង ឃុំជ័យជោគ ស្រុកបូរីជលសា និង ឃុំព្រៃខ្លា ឃុំក្រពុំឈូក ស្រុកកោះអណ្តែត មានផ្ទៃក្រឡាទំហំ **៩១៩** ហិកតា (ប្រាំបួនរយដប់ប្រាំបួនហិកតា) ដូចមានផែនទីភ្ជាប់ ជាឧបសម្ព័ន្ធ ជាប្រព័ន្ធខ្សែព្រំបិទ កំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកា : **a** (501481, 1188861); **b** (501537, 1186000); **c** (504741, 1186000); **d** (504722, 1188861) ។

២-តំបន់ទ្រនាប់ មានទីតាំងព័ទ្ធជុំវិញតំបន់ស្នូលស្ថិតនៅក្នុងឃុំកំពង់ក្រសាំង និង ឃុំជ័យជោគ ស្រុកបុរីជលសា និង ឃុំព្រៃខ្លា ឃុំក្រពុំឈូក ឃុំព្រៃយុថ្កា ឃុំរមេញ ស្រុកកោះអណ្តែត ។

**មាត្រា ៦.-**

តំបន់ស្នូលជាតំបន់ មានសារប្រយោជន៍ សម្រាប់ការពារ និង អភិរក្សធនធានធម្មជាតិយ៉ាងហ្មត់ចត់ ដើម្បីថែរក្សាឱ្យបានគង់វង្ស នូវព្រៃលិចទឹក មច្ឆជាតិ ប្រភពចំណីអាហារសត្វក្រៀល និង សត្វស្លាបផ្សេងទៀត ។ តំបន់ស្នូលអនុញ្ញាតឱ្យ មានសកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រ ការអង្កេតតាមដាន បម្រើសេវាកម្មទេសចរណ៍ធម្មជាតិ និង ការនេសាទត្រី ប្រកបដោយនិរន្តរភាព ដោយមិនអនុញ្ញាតឱ្យមាន សកម្មភាពប្រើប្រាស់ ដែលធ្វើឱ្យរេចរឹល ឬ បំផ្លាញដល់ជីវៈចម្រុះឡើយ ។

តំបន់ទ្រនាប់ជាតំបន់ដែលគ្របដណ្តប់ ដោយវាលស្មៅដីសើម ជាតំបន់សម្រាប់បម្រើវិស័យកសិកម្ម ដឹកជញ្ជូនទំនិញឆ្លងកាត់ និង អភិវឌ្ឍន៍ផ្សេងៗ ដោយធានានិរន្តរភាពនៃធនធានមច្ឆជាតិ ប្រភពធនធានទឹក និង ជម្រកសត្វក្រៀល និង សត្វស្លាបផ្សេងទៀតក្នុងតំបន់នោះ ។

**មាត្រា ៧.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានសមត្ថកិច្ចរៀបចំ និង គ្រប់គ្រងតំបន់គ្រប់គ្រង និង អភិរក្សដែនបម្រុងសត្វក្រៀល និង សត្វស្លាបផ្សេងទៀត ដោយសហការជាមួយក្រសួងពាក់ព័ន្ធ និង អាជ្ញាធរមូលដ្ឋាន ដើម្បីធានានូវការអភិវឌ្ឍធនធានធម្មជាតិប្រកបដោយនិរន្តរភាព សម្រាប់ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋក្នុងតំបន់នោះ ។

ដំណើរការនៃការរៀបចំ និង គ្រប់គ្រងតំបន់គ្រប់គ្រង និង អភិរក្សដែនបម្រុងសត្វក្រៀល និង សត្វស្លាបផ្សេងទៀត ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ២០០៧

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង
- ដូចមាត្រា ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ


10°46'
10°44'
10°42'
105°
105°2'
105°4'
105°6'
1182
1184
1186
1188
1190
1192
498
500
502
504
506
508
510
512
5 Km
N
(Coordinate System)
(Projection)
(Zone)
(Horizontal Datum) (Indian 1960)
(Spheroid) (Everest)
(UTM Grid)
GIS/FA